**សកម្មភាព** ៖ **ល្បែងធ្វើប័ណ្ណប្រៃសណីយ៍**

**សិក្សាសង្គម**

បំណិនទំនាក់ទំនង (អត្តសញ្ញាណរបស់ខ្លួន)

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់ពីនាមត្រកូល នាមខ្លួន អាស័យដ្ឋាន ចំនួនសមាជិកគ្រួសារ។

ប្រាប់ពីរបៀបបត់សន្លឹកកិច្ចការ បិទ បត់ គូរ រចនា បង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលបង្កើតឡើងបាន។

**កុមារអាចប្រាប់បានពីនាមត្រកូល នាមខ្លួន**

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី? "

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សន្លឹកកិច្ចការ និងខ្មៅដៃពណ៌

**ការរៀបចំ** ៖ បោះពុម្ពសន្លឹកកិច្ចការ

**សេក្តីណែនាំ៖**

1. សួរក្មេងៗថា៖ តើកូនៗធ្លាប់មានអ្នកផ្ញើសំបុត្រ ឬ កញ្ចប់ឥវ៉ាន់ពីមុនមកដែរឬទេ?
2. ពិភាក្សាពីសេវាកម្មនៅការិយាល័យប្រៃសណីយ៍។
   ឧទាហរណ៍៖ តើកូនៗស្គាល់ អ្នកធ្វើការនៅក្នុងការិយាល័យប្រៃសណីយដែរឬទេ?
   តើការិយាល័យប្រៃសណីយ៍គេធ្វើអ្វីដែរ?
   តើការិយាល័យប្រៃសណីយ៍ត្រូវការអ្វីខ្លះទើបអាចផ្ញើសំបុត្រ ឬ កញ្ចប់ឥវ៉ាន់បាន?
   តើគេធ្វើយ៉ាងណាទើបដឹងថាសំបុត្រទាំងនោះសម្រាប់អ្នកណា?
3. សួរពួកគេប្រសិនបើពួកគេស្គាល់នាមប្រកូល និងអាស័យដ្ឋានរបស់ពួកគេ ។
   តើកូនៗឈ្មោះអ្វី? តើកូនៗរស់នៅកន្លែងណា? អាស័យដ្ឋានឈ្មោះអ្វី?
4. ចែកក្រដាសសន្លឹកកិច្ចការ និងខ្មៅដៃពណ៌។ នឹងពន្យល់ប័ណ្ណប្រៃសណីយ៍។
5. បង្ហាញពួកគេពីការបត់ក្រដាសសន្លឹកកិច្ចការ

6. បង្ហាញពួកគេ ពីខ្នងរបស់ប័ណ្ណប្រៃសណីយ៍ និងអ្វីដែលត្រូវសរសេរនៅលើបន្ទាត់ នាមប្រកូល និងអាសយដ្ឋានរស់នៅបច្ចុប្បន្នរី(ផាត់ព៌ណ គូររូបភាពផ្សេងៗដើម្បីសម្គាល់ថាជារបស់ខ្លួន។
7. សួរពួកគេឱ្យគូររូបនៅផ្ទៃក្រដាសដែលនៅម្ខាងទៀត និងរចនាត្រាដោយខ្លួនឯង។
8. ប្រសិនបើពួកគេបានដឹង អាចសរសេរឈ្មោះរបស់ពួកគេ និងអាសយដ្ឋាន(សួរក្មេងៗ)
9. សម្រាប់ក្មេងៗដែលមិនបានសរសេរឈ្មោះ និងអាសយដ្ឋានរបស់ពួកគាត់ទេ អ្នកអាចសរសេរឈ្មោះរបស់អ្នក និងអាសយដ្ឋានសាលារៀន នៅលើក្ដារខៀន ដើម្បីឱ្យក្មេងៗអាចកត់សម្លងបាន។